លេខ ៣៥ ចេញផ្សាយថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែមេសា ឆ្នាំ២០២៤

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញអំពីការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសង្គម

នាព្រឹកថ្ងៃចន្ទ ៨ រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហការជាមួយមន្ទីរកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទខេត្តសៀមរាប បានរៀបចំវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញអំពីការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសង្គម - ESMS Info.Sheet. ក្រោមការដឹកនាំរបស់ **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1។ វគ្គបណ្តុះបណ្តាលផ្តោតសំខាន់លើការពង្រឹងសមត្ថភាពដល់មន្ត្រីឥណទានរបស់ស្ថាប័នហិរញ្ញវត្ថុទាំងពីរលើការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសង្គម ដែលជាលក្ខខណ្ឌតម្រូវរបស់ ADB ក្នុងឯកសាស្នើសុំឥណទានរបស់គម្រោង។

កម្មវិធីនេះ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, តំណាងអង្គភាពគ្រប់គ្រងគម្រោងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងធនាគារស្ថាបនា និងមន្ត្រីបង្គោលនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តគោលដៅរបស់គម្រោង។

## មាតិកា


- វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញអំពីការបំពេញទម្រង់ព័តិមានផលប៉ះពាល់បរិស្ថាន និងសង្គម ទំព័រទី១
- សិក្ខាសាលាស្តីពី “ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍” ទំព័រទី២
- ពិធី "លៀងសាយភោជន សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០២៤" របស់សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា ទំព័រទី២
- កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) ទំព័រទី៣
- វគ្គបណ្តុះបណ្តាលចែករំលែកចំណេះដឹងស្តីពី “ការយល់ដឹងពីប្រព័ន្ធ Artificial Intelligence (AI)” ទំព័រទី៣
- ពិធីសំណេះសំណាលសួរសុខទុក្ខនិវត្តជនរបស់សមាគមសង្គហៈមិត្តបុគ្គលិក មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) ទំព័រទី៣
- កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី១៨ ទំព័រទី៤
- កម្មវិធីសប្បុរសធម៌ នៅមជ្ឈមណ្ឌលទារក និងកុមារជាតិ ទំព័រទី៤
- ពិធីចម្រើនព្រះបរិត្ត អបអរពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ និងសូត្រមន្តលើករាសី ទំព័រទី៤
- ជំនួបជាមួយក្រុមហ៊ុន V Connect Cambodia ទំព័រទី៥
- សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងសៀវភៅឯកសារសម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ "គណនេយ្យភាពសមិទ្ធកម្ម" ទំព័រទី៥
- ជំនួបជាមួយក្រុមហ៊ុន Cloudnet Cambodia ទំព័រទី៦
- កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៤ និងទិសដៅការងារបន្ត" របស់ **ន.ប.ធ.** ទំព័រទី៦
- កិច្ចប្រជុំពិភាក្សាការងារជាមួយក្រសួងអប់រំ យុវជន និងកីឡា ទំព័រទី៦
- កិច្ចប្រជុំពិភាក្សាការងារជាមួយក្រសួងបរិស្ថាន ទំព័រទី៧
- ការនាំយកថវិកាដែលជាការបរិច្ចាគពីថ្នាក់ដឹកនាំ និងមន្ត្រីនៃ **ន.ប.ធ.** ប្រគល់ជូនមូលនិធិគន្ធបុប្ផាកម្ពុជា ទំព័រទី៧
- ជំនួបជាមួយសមាគមស្បែកជើងកម្ពុជា ទំព័រទី៨
- កិច្ចប្រជុំពិភាក្សាការងារជាមួយក្រសួងយុត្តិធម៌ ទំព័រទី៨
- កិច្ចប្រជុំពិភាក្សាការងារជាមួយធនាគារជាតិនៃកម្ពុជា ទំព័រទី៨
- កម្មវិធីបណ្តុះបណ្តាលស្តីពី “យន្តការបរធនបាលកិច្ចនៅកម្ពុជា” សម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ធនាគារ វីង (ខេមបូឌា) ម.ក ទំព័រទី៩




អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាព៖ វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញអំពីការបំពេញទម្រង់ព័ត៌មានផលប៉ះពាល់បរិស្ថាន និងសង្គម។



រូបភាព៖ សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍"។

## សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍"

នាព្រឹកថ្ងៃអង្គារ ៩ រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាស្តីពី **"ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍"** នៅខេត្តសៀមរាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជានាយកគម្រោង **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1 និង **ឯកឧត្តម អ៊ឹង គឹមលាង** អភិបាលរង នៃគណៈអភិបាលខេត្តសៀមរាប។

កម្មវិធីនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងធ្វើការណែនាំបន្ថែមដល់សមាជិកសហគមន៍ និងភ្នាក់ងារឥណទានគម្រោង ACSEP តាមខេត្ត ស្រុក និងឃុំគោលដៅ, ផ្តល់ព័ត៌មានអំពីការផ្តល់ប្រាក់កម្ចី របស់គម្រោង ACSEP ដល់សមាជិកសហគមន៍កសិកម្ម ដែលមានក្នុងបញ្ជីក្រុមគោលដៅ និងកសិករចិញ្ចឹមមាន់ស្រុក និងបង្ហាញអំពីនីតិវិធីដែលអាចទទួលបានឥណទានដល់សមាជិកសហគមន៍កសិកម្ម ដែលមានបំណងស្វែងរកទុនគាំទ្រផែនការអាជីវកម្មលើវិស័យកសិកម្ម។

កម្មវិធីនេះ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, តំណាងអង្គភាពគ្រប់គ្រងគម្រោងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តំណាងក្រសួងអភិវឌ្ឍន៍ជនបទ និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីររួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។

## ពិធី "លៀងសាយភោជន សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០២៤" របស់សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

នាថ្ងៃអង្គារ ៩រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធី "លៀងសាយភោជន សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០២៤" របស់សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា នៅ ភី អេច ហ្គ្រេន ហល (បុរីប៉េងហួត បឹងស្នោ)។



រូបភាព៖ ពិធី "លៀងសាយភោជន សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០២៤" របស់សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃព្រហស្បតិ៍ ១១ រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាងរបាយការណ៍សមិទ្ធផលឆ្នាំ២០២៣ របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងរបាយការណ៍ត្រួតពិនិត្យការអនុវត្តថវិកាប្រចាំឆ្នាំ២០២៣ របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** អនុប្រធាន **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។




រូបភាព៖ កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។

## វគ្គបណ្តុះបណ្តាលចែករំលែកចំណេះដឹងស្តីពី "ការឈ្វេងយល់ពីប្រព័ន្ធ Artificial Intelligence (AI)"

នាព្រឹកថ្ងៃសុក្រ ១២រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៥ខែមេសា ឆ្នាំ២០២៤, និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំវគ្គបណ្តុះបណ្តាលចែករំលែកចំណេះដឹងស្តីពី **"ការឈ្វេងយល់ពីប្រព័ន្ធ Artificial Intelligence (AI)"** ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងមាន **លោកបណ្ឌិត ឡាយ គីរី** ជាវាគ្មិនកិត្តិយស ព្រមទាំងមានការអញ្ជើញចូលរួមដោយផ្ទាល់ពីថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃ **ន.ប.ធ.** មន្ត្រីតំណាងមកពីនិយ័តករ និងអង្គភាពក្រោមឱវាទនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) នៅទីស្តីការ **អ.ស.ហ.**។ ដូចមានកំណត់ក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា, វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងស្របតាមផែនការសកម្មភាពរបស់ **ន.ប.ធ.** ក្នុងការចាប់យកនវានុវត្តន៍បច្ចេកវិទ្យា និងក្នុងគោលបំណងដើម្បីសិក្សាឈ្វេងយល់ពីដំណើរការ, របៀបប្រើប្រាស់ និងអត្ថប្រយោជន៍របស់ AI ក្នុងការជួយសម្រួលដល់ការអនុវត្តការងារប្រចាំថ្ងៃ, បង្កើនផលិតភាពការងារ, និងជាទុនចំណេះដឹងបន្ថែមក្នុងការចូលរួមចំណែកអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យានៅក្នុងវិស័យបរធនបាលកិច្ច ក៏ដូចជាវិស័យហិរញ្ញវត្ថុជារួម។



រូបភាព៖ វគ្គបណ្តុះបណ្តាលចែករំលែកចំណេះដឹងស្តីពី "ការឈ្វេងយល់ពីប្រព័ន្ធ Artificial Intelligence (AI)"។

## ពិធីសំណេះសំណាលសួរសុខទុក្ខនិវត្តជនរបស់សមាគមសង្គហៈមិត្ត បុគ្គលិក មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ)

នាព្រឹកថ្ងៃអង្គារ ១កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ បានអញ្ជើញចូលរួមពិធីសំណេះសំណាលសួរសុខទុក្ខនិវត្តជនរបស់សមាគមសង្គហៈមិត្ត បុគ្គលិក មន្ត្រីរាជការនៃ កសហវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និវត្តជនរបស់សមាគមសង្គហៈមិត្ត បុគ្គលិក មន្ត្រីរាជការនៃ កសហវ នៅសាលាជាតិគយ រាជធានីភ្នំពេញ។




**រូបភាព៖** ពិធីសំណេះសំណាលសួរសុខទុក្ខនិវត្តជនរបស់សមាគមសង្គហៈមិត្តបុគ្គលិក មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ)។

## កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី១៨

នាព្រឹកថ្ងៃពុធ ២កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** នៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។




**រូបភាព៖** កិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី១៨។

## កម្មវិធីសប្បុរសធម៌ នៅមជ្ឈមណ្ឌលទារក និងកុមារជាតិ

នៅព្រឹកថ្ងៃព្រហស្បតិ៍ ៣កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងលោកជំទាវ រួមដំណើរដោយ ឯកឧត្តមអគ្គនាយករង លោក លោកស្រី ជាថ្នាក់ដឹកនាំបច្ចេកទេស និងសហការីនៃ **ន.ប.ធ.** បានចុះសួរសុខទុក្ខ ក៏ដូចជាបន្តលើកទឹកចិត្តដល់ក្មេងៗកំព្រា គ្មានអាណាព្យាបាល និងមានពិការភាព ទាំងការរស់នៅ និងហូបចុក ក៏ដូចជាលើកទឹកចិត្ត និងគាំទ្រដល់បុគ្គលិកបម្រើការងារមើលថែទាំក្មេងៗនៅក្នុងមជ្ឈមណ្ឌលទារក និងកុមារជាតិ ព្រមទាំងមានការរៀបចំជាអាហារ និងភេសជ្ជៈជូនដល់បុគ្គលិក និងក្មេងៗនៅក្នុងមជ្ឈមណ្ឌល។




**រូបភាព៖** កម្មវិធីសប្បុរសធម៌ នៅមជ្ឈមណ្ឌលទារក និងកុមារជាតិ។

## ពិធីចម្រើនព្រះបរិត្ត អបអរពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ និងសូត្រមន្តលើករាសី

នារសៀលថ្ងៃសុក្រ ៤កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសហការី បានអញ្ជើញចូលរួមពិធីចម្រើនព្រះបរិត្ត អបអរពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ និងសូត្រមន្តលើករាសី សិរីសួស្តី ឆ្នាំចាស់ផ្លាស់ចូលឆ្នាំថ្មី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) និងជាអគ្គលេខាធិការនៃអគ្គលេខាធិការ-ដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) នៅទីស្តីការ **អ.ស.ហ.**។

ពិធីនេះមានការអញ្ជើញចូលរួមពី ឯកឧត្តមប្រតិភូទទួលបន្ទុកជាអគ្គនាយក និងឯកឧត្តមអគ្គនាយកនៃនិយ័តករក្រោមឱវាទ **អ.ស.ហ.**, ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.**។



រូបភាព៖ ពិធីចម្រើនព្រះបរិត្ត អបអរពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ និងសូត្រមន្តលើករាសី សិរីសួស្តី។

## ជំនួបជាមួយក្រុមហ៊ុន V Connect Cambodia

នាព្រឹកថ្ងៃព្រហស្បតិ៍ ១០កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤ **ឯកឧត្តម ស៊ុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញទទួលជួបជាមួយក្រុមហ៊ុន V Connect Cambodia ដែលជាក្រុមហ៊ុនផ្តល់សេវាកម្មបច្ចេកវិទ្យាព័ត៌មានវិទ្យានាំមុខមួយក្នុងស្រុក។ តំណាងក្រុមហ៊ុន បានធ្វើបទបង្ហាញអំពីដំណើរការនៃប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យារបស់ក្រុមហ៊ុន ដែលអាចមានផលប្រយោជន៍ និងអាចចូលរួមចំណែកសម្រាប់ការគ្រប់គ្រងប្រតិបត្តិការបរធនបាលកិច្ចនៅកម្ពុជា។



រូបភាព៖ ជំនួបជាមួយក្រុមហ៊ុន V Connect Cambodia។

## សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងសៀវភៅឯកសារសម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ "គណនេយ្យភាពសមិទ្ធកម្ម"

នាថ្ងៃព្រហស្បតិ៍ ១០កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ស៊ុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម ឈី សាកល** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយ **លោក ជី គន់នី** ប្រធានការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុនៃនាយកដ្ឋានកិច្ចការទូទៅ បានអញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងសៀវភៅ "Public Finance Management Reform for Structural Transformation: Fiscal Coordination between National and Sub-National Administrations in Cambodia" និង "Economic and social status, and Cambodia on Fiscal Sustainability In An Open Economy" ដើម្បីជាឯកសារសម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ "គណនេយ្យភាពសមិទ្ធកម្ម" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម យ៉េត វីណែល** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ព្រមទាំងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់-ដឹកនាំក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៅសណ្ឋាគារ Raffle le Royal។



រូបភាព៖ សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងសៀវភៅឯកសារសម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ "គណនេយ្យភាពសមិទ្ធកម្ម"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## ជំនួបជាមួយក្រុមហ៊ុន Cloudnet Cambodia

នាព្រឹកថ្ងៃសុក្រ ១១កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញទទួលជួបជាមួយក្រុមហ៊ុន Cloudnet Cambodia ដែលជាក្រុមហ៊ុនផ្តល់សេវាកម្មបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងស្រុក។ តំណាងក្រុមហ៊ុន បានធ្វើបទបង្ហាញអំពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា ដែលក្រុមហ៊ុនបានអភិវឌ្ឍន៍កន្លងមក និងមុខងារផ្សេងៗសម្រាប់ការគ្រប់គ្រងកិច្ចដំណើរការរដ្ឋបាល និងប្រតិបត្តិការស្ថាប័នក្នុងក្របខណ្ឌ E-Government។



**រូបភាព៖** ជំនួបជាមួយក្រុមហ៊ុន Cloudnet Cambodia។

## កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៤ និងទិសដៅការងារបន្ត" របស់ ន.ប.ធ.

នារសៀលថ្ងៃសុក្រ ១១កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំកិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៤ និងទិសដៅការងារបន្ត" របស់ **ន.ប.ធ.** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។

នៅក្នុងកិច្ចប្រជុំនេះ មានការធ្វើបទបង្ហាញពីគ្រប់នាយកដ្ឋានចំណុះនៃ **ន.ប.ធ.** ដោយបានបង្ហាញអំពីសមិទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៤ និងទិសដៅការងារបន្ត ព្រមទាំងមានការពិភាក្សាយ៉ាងផុសផុលក្នុងកម្រិតមន្ត្រី និងថ្នាក់ដឹកនាំរបស់ **ន.ប.ធ.** លើបញ្ហាប្រឈម និងដំណោះស្រាយដែលបានអនុវត្តកន្លងមក និងលើកឡើងនូវវិធីសាស្ត្រដើម្បីត្រៀមខ្លួនក្នុងការអនុវត្តការងារនៅត្រីមាសបន្ទាប់ឱ្យកាន់តែល្អប្រសើរថែមទៀត។



**រូបភាព៖** កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៤ និងទិសដៅការងារបន្ត" របស់ **ន.ប.ធ.**។

## កិច្ចប្រជុំពិភាក្សាការងារជាមួយក្រសួងអប់រំ យុវជន និងកីឡា

នារសៀលថ្ងៃចន្ទ ១៤ កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៤ ដោយទទួលបានការអនុញ្ញាតជាគោលការណ៍ដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំក្រុមការងាររៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចសម្រាប់រយៈពេល ១០ ឆ្នាំ (២០២៤-២០៣៣) ជួបប្រជុំពិភាក្សាការងារជាមួយក្រសួងអប់រំ យុវជន និងកីឡា ដែលតំណាងដោយ **ឯកឧត្តមបណ្ឌិត សាន វឌ្ឍនា** អនុរដ្ឋលេខាធិកា ក្រសួងអប់រំ យុវជន និងកីឡា និង **ឯកឧត្តម ទេព តិយ៉ោវិទ្ធ** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ។ កិច្ចប្រជុំបានផ្តោតការពិភាក្សាអំពីយន្តការបរធនបាលកិច្ច បច្ចុប្បន្នភាពនៃទីផ្សារបរធនបាលកិច្ចនិងការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យបរធនបាលកិច្ច ការផ្តល់ធាតុចូលពាក់ព័ន្ធនឹងការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចសម្រាប់រយៈពេល ១០ ឆ្នាំ (២០២៤-២០៣៣) ការពិនិត្យលទ្ធភាពលើការបង្កើតកិច្ចសហប្រតិបត្តិការក្នុងការលើកកម្ពស់ និងបញ្ជ្រាបការយល់ដឹងអំពីវិស័យបរធនបាលកិច្ចជាមួយគ្រឹះស្ថានអប់រំ និងក្នុងកម្មវិធីសិក្សា និងពិភាក្សាអំពីដំណោះស្រាយចំពោះបញ្ហាប្រឈមនានាក្នុងការចាប់យកកាលានុវត្តភាព និងការទាញយកអត្ថប្រយោជន៍ពីវិស័យបរធនបាលកិច្ច ផងដែរ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាព៖ កិច្ចប្រជុំពិភាក្សាការងារជាមួយក្រសួងអប់រំ យុវជន និងកីឡា។




រូបភាព៖ កិច្ចប្រជុំពិភាក្សាការងារជាមួយក្រសួងបរិស្ថាន។

## កិច្ចប្រជុំពិភាក្សាការងារជាមួយក្រសួងបរិស្ថាន

នាព្រឹកថ្ងៃអង្គារ ១៥ កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៤ ដោយទទួលបានការអនុញ្ញាតជាគោលការណ៍ដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំក្រុមការងាររៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចសម្រាប់រយៈពេល ១០ ឆ្នាំ (២០២៤-២០៣៣) ជួបប្រជុំពិភាក្សាការងារជាមួយក្រសួងបរិស្ថានដែលតំណាងដោយ **ឯកឧត្តម ពុទ្ធ សុរិទ្ធី** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន និងសហការី។ កិច្ចប្រជុំបានផ្តោតលើការពិភាក្សាអំពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច, ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធដែលមានជាធរមាន, ប្រភេទនៃបរធនបាលកិច្ច និងប្រតិបត្តិការ ដែលគ្រប-ដណ្តប់ទាំងបរធនបាលកិច្ចបរិស្ថានផងដែរ ព្រមទាំងទិសដៅផែនការសកម្មភាពការងារ និងកិច្ចសហប្រតិបត្តិការ ដែលអាចមានរវាងវិស័យបរធនបាលកិច្ច និងវិស័យបរិស្ថាន។

## ការនាំយកថវិកាដែលជាការបរិច្ចាគពីថ្នាក់ដឹកនាំ និងមន្ត្រីនៃ ន.ប.ធ. ប្រគល់ជូនមូលនិធិគន្ធបុប្ផាកម្ពុជា

នាព្រឹកថ្ងៃព្រហស្បតិ៍ ២រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃ **ន.ប.ធ.**, **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ, **កញ្ញា ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច និងសហការី បានពាំនាំយកថវិកាដែលជាការបរិច្ចាគពីថ្នាក់ដឹកនាំ និងមន្ត្រីនៃ **ន.ប.ធ.** ប្រគល់ជូនមូលនិធិគន្ធបុប្ផាកម្ពុជា ដើម្បីចូលរួមចំណែកក្នុងការជួយសង្គ្រោះជីវិតកុមារកម្ពុជា និងធានានិរន្តរភាពនៃកិច្ចដំណើរការរបស់មន្ទីរពេទ្យគន្ធបុប្ផាកម្ពុជា។




រូបភាព៖ សកម្មភាពនាំយកថវិកាដែលជាការបរិច្ចាគពីថ្នាក់ដឹកនាំ និងមន្ត្រីនៃ **ន.ប.ធ.** ប្រគល់ជូនមូលនិធិគន្ធបុប្ផាកម្ពុជា។

## ជំនួបជាមួយសមាគមស្បែកជើងកម្ពុជា

នាព្រឹកថ្ងៃសុក្រ ៣រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញទទួលជួបជាមួយសមាគមស្បែកជើងកម្ពុជា តំណាងដោយ **លោក** Ben Kao អគ្គលេខាធិកានៃសមាគមស្បែកជើងកម្ពុជា ក្នុងគោលបំណងដើម្បីពិភាក្សាអំពីឈ្វេងយល់អំពីការអភិវឌ្ឍទីផ្សារបរធនបាលកិច្ច កាលានុវត្តភាពសម្រាប់ការវិនិយោគនៅកម្ពុជា តាមរយៈយន្តការបរធនបាលកិច្ច និងលទ្ធភាពធ្វើកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌបច្ចេកទេសដែលអាចមាន នាពេលខាងមុខផងដែរ នៅទីស្តីការ **ន.ប.ធ.**។




*រូបភាព៖* ជំនួបជាមួយសមាគមស្បែកជើងកម្ពុជា។

## កិច្ចប្រជុំពិភាក្សាការងារជាមួយក្រសួងយុត្តិធម៌

នារសៀលថ្ងៃចន្ទ ៦រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ដោយទទួលបានការអនុញ្ញាតជាគោលការណ៍ដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំក្រុមការងាររៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច សម្រាប់រយៈពេល ១០ ឆ្នាំ (២០២៤-២០៣៣) ជួបប្រជុំពិភាក្សាការងារជាមួយក្រសួងយុត្តិធម៌ ដែលតំណាងដោយ **ឯកឧត្តម យ៉េម ផារ៉ុត** ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី អមដោយសហការី។

កិច្ចប្រជុំបានផ្តោតការ ពិភាក្សាអំពីក្របខណ្ឌអភិវឌ្ឍន៍ស្ថាប័ន, ក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិដែលមានជាធរមាន, ការជំរុញនិងការពង្រឹងការអនុវត្តច្បាប់, និងកិច្ចសហការដែលអាចមានក្នុងក្របខណ្ឌដោះស្រាយវិវាទ, ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយ ក៏ដូចជាកិច្ចសហប្រតិបត្តិការផ្សេងទៀត រវាងក្រសួងយុត្តិធម៌ និងនិយ័តករបរធនបាលកិច្ច។




*រូបភាព៖* កិច្ចប្រជុំពិភាក្សាការងារជាមួយក្រសួងយុត្តិធម៌។

## កិច្ចប្រជុំពិភាក្សាការងារជាមួយធនាគារជាតិនៃកម្ពុជា

នារសៀលថ្ងៃអង្គារ ៧រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ ដោយទទួលបានការអនុញ្ញាតជាគោលការណ៍ដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃនិយ័តករបរធន-បាលកិច្ច (**ន.ប.ធ.**) បានដឹកនាំក្រុមការងាររៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចសម្រាប់រយៈពេល ១០ ឆ្នាំ (២០២៤-២០៣៣) ជួបប្រជុំពិភាក្សាការងារជាមួយធនាគារជាតិនៃកម្ពុជា ដែលតំណាងដោយ **លោកស្រី ម៉ក់ រស្មី** ប្រធាននាយកដ្ឋានគោលនយោបាយបទប្បញ្ញត្តិនិងវាយតម្លៃហានិភ័យ អមដោយសហការី។

កិច្ចប្រជុំបានផ្តោតការពិភាក្សាអំពីវឌ្ឍនភាពនៃវិស័យបរធនបាលកិច្ច និងការរីកចម្រើនយ៉ាងឆាប់រហ័សក្នុងការប្រើប្រាស់សេវារក្សាសុវត្ថិភាព ឬរក្សាទុកនៅក្នុងវិស័យបរធនបាលកិច្ច, ទស្សនាទាន និងការចែករំលែកអំពីការត្រួតពិនិត្យ និងការគ្រប់គ្រងហានិភ័យ និងកិច្ចសហប្រតិបត្តិការដែលអាចមានរវាងធនាគារជាតិនៃកម្ពុជា និង **ន.ប.ធ.** ក្នុងក្របខ័ណ្ឌបណ្តុះបណ្តាលចែករំលែកចំណេះដឹង និងការកសាងសមត្ថភាពមន្ត្រីផងដែរ។




រូបភាព៖ កិច្ចប្រជុំពិភាក្សាការងារជាមួយធនាគារជាតិនៃកម្ពុជា។

## កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" សម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ធនាគារ វីង (ខេមបូឌា) ម.ក

នារសៀល ថ្ងៃអង្គារ ៧រោច ខែចេត្រ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមជាមួយ **លោក** Han Peng Kwang អគ្គនាយក នៃធនាគារ វីង (ខេមបូឌា) ម.ក ជាអធិបតីក្នុងកម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" សម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ធនាគារ វីង (ខេមបូឌា) ម.ក ដែលជាធនាគារទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ធ្វើជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច។ កម្មវិធីបណ្តុះបណ្តាលនេះ រៀបចំផ្ទាល់នៅអគារ វីង និង តាមរយៈអនឡាញ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងបុគ្គលិកទទួលបន្ទុកមកពីទីស្នាក់ការកណ្តាល និងបណ្តាសាខានៅរាជធានីភ្នំពេញ និងសាខាតាមបណ្តាខេត្តរបស់ធនាគារ វីង (ខេមបូឌា) ម.ក ដែលធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងបរធនបាលកិច្ច (សេវារក្សាសុវត្ថិភាព ឬរក្សាទុក)។







រូបភាព៖ កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" សម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ធនាគារ វីង (ខេមបូឌា) ម.ក។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888